ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# គម្រោងអាជីវកម្ម
# នៃការដាំដុះដំណាំកាហ្វេ






រៀបចំដោយ
នាយកដ្ឋានគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ
ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ធ.អ.ជ.ក.)

ខែមេសា ឆ្នាំ២០២៦

## មាតិកា


**១-សេចក្តីផ្តើម** ........ ១

**២-ផលិតកម្មកាហ្វេ និងទីផ្សារក្នុងពិភពលោក** ........ ១

២.១- ផលិតកម្មកាហ្វេនៅក្នុងពិភពលោក ........ ១

២.២- ទីផ្សារកាហ្វេក្នុងពិភពលោក ........ ២

**៣-ផលិតកម្មកាហ្វេនៅប្រទេសកម្ពុជា និងប្រទេសជិតខាង** ........ ២

៣.១- ផលិតកម្មកាហ្វេនៅប្រទេសកម្ពុជា និងប្រទេសជិតខាង ........ ២

៣.២- តារាងផលិតកម្មកាហ្វេនៅកម្ពុជា វៀតណាម ឡាវ និងថៃ ........ ២

**៤-ការអនុវត្តការដាំដុះ** ........ ២

៤.១- ការជ្រើសរើសទីតាំង និងដី ........ ២

៤.២- ប្រព័ន្ធស្រោចស្រព ........ ៣

៤.៣- ការជ្រើសរើសពូជកាហ្វេ ........ ៣

៤.៣.១- អារ៉ាប៊ីកា (Arabica coffee) ........ ៣

៤.៣.២- រ៉ូប៊ូស្តា (Robusta) ........ ៣

៤.៤- ការរៀបចំល្បាយដីសម្រាប់បណ្តុះកាហ្វេ ........ ៤

៤.៤.១- បណ្តុះពូជដោយគ្រាប់ ........ ៤

៤.៤.២- ពូជកាត់បណ្តុះគ្រាប់ ........ ៥

៤.៥- វិធីដាំដុះ ........ ៥

៤.៥.១- ការរៀបចំរណ្តៅ ........ ៥

៤.៥.២- លក្ខណៈកូនកាហ្វេ ........ ៦

៤.៥.៣- ការដាក់កូនដាំ ........ ៦

**៥-ការថែទាំ** ........ ៧

៥.១- ការស្រោចទឹក ........ ៧

៥.២- សារធាតុចិញ្ចឹម និងការដាក់ជីដំណាំកាហ្វេ ........ ៧

៥.២.១- សារធាតុចិញ្ចឹម ........ ៧

៥.២.២- ជីធម្មជាតិ ឬជីសរីរាង្គ ........ ៧

៥.២.៣- ជីគីមី ឬជីអសរីរាង្គ ........ ៧

៥.២.៤- ការដាក់ជីដំណាំកាហ្វេ ........ ៨

៥.៣.- ការតាក់តែងមែក (Pruning) និងការកាត់ដើម (Stumping)......... ..................... ៩
៥.៣.១- ការកាត់តែងមែក (Pruning) ........................................................ ៩
៥.៣.២- ការកាត់ដើម (Stumping) ........................................................ ៩
៥.៤.- ការគ្រប់គ្រងស្មៅ......... ........................................................ ១០
៥.៥- សត្វល្អិតបំផ្លាញ........................................................ ១០
៥.៥.១- ចៃសលើកាហ្វេ (Coffee Mealybugs) ........................................ ១០
៥.៥.២- ចៃក្រមួន (Scales) ........................................................ ១០
៥.៥.៣- ខ្ទួតចោះផ្លែកាហ្វេ (Coffee Berry Borer)........................................ ១០
៥.៥.៤- ពពួកចៃ (Aphids) ........................................................ ១១
៥.៥.៥- ដង្កូវស៊ីរូងដើម (Coffee stem borer) ........................................ ១១
៥.៥.៦- ចៃអង្គ្រង់ ឬខ្ទុង ........................................................ ១១
៥.៦- ប្រភេទជំងឺ........................................................ ១២
៥.៦.១- ជំងឺស្លឹកច្រែះ (Coffee Leaf Rust)........................................ ១២
៥.៦.២- ជំងឺពងទឹកលើផ្លែកាហ្វេ (Red blister Disease) ........................ ១២
៥.៦.៣- ជំងឺពងទឹកលើផ្លែកាហ្វេ (Root Rot Disease) ........................ ១៣
**៦-ការប្រមូលផល** ........................................................ **១៣**
៦.១- ការផ្តល់ផល និងការប្រមូលផល........................................................ ១៣
៦.១- តារាងទិន្នផល........................................................ ១៤
**៧-ការវិភាគសេដ្ឋកិច្ចលើការដាំដំណាំកាហ្វេ**........................................ **១៥**
៧.១- តារាងវិភាគសេដ្ឋកិច្ចត្រឹមផ្លែស្រស់ ........................................ ១៥
៧.២- តារាងសង្ខេបបង្ហាញពីខាត- ចំណេញសម្រាប់ការលក់ផ្លែស្រស់ ........................ ១៩
៧.៣- ថ្លៃដើមផលិតផ្លែកាហ្វេស្រស់........................................................ ១៩
៧.៤- ពីកាហ្វេស្រស់ទាំងសម្បកមកកាហ្វេស្ងួតទាំងសម្បក........................................ ២០
៧.៥- បរិមាណនៅសល់ក្រោយពីការបកសម្បកចេញ........................................ ២០
៧.៦- ការសម្ងួតលើកទី ២ ក្រោយយកសម្បកចេញ សំណើម........................................ ២០
៧.៧- ការស្រកស្រុតក្រោយពេលលីង និងកិនជាម្សៅកាហ្វេ........................................ ២១
៧.៨- តារាងវិភាគសេដ្ឋកិច្ចគ្រាប់កាហ្វេស្ងួត........................................ ២១
៧.៩- តារាងសង្ខេបបង្ហាញពីខាត- ចំណេញសម្រាប់គ្រាប់កាហ្វេស្ងួត........................ ២៥
៧.១០- ថ្លៃដើមផលិតគ្រាប់កាហ្វេស្ងួត ........................................................ ២៥

៨-បញ្ហាប្រឈម និងដំណោះស្រាយ ........................................................................ ២៥
៩-សេចក្តីសន្និដ្ឋាន .................................................................................................. ២៧
១០-ប្រភពឯកសារ...................................................................................................... ២៨

# ដំណាំកាហ្វេ

## ១-សេចក្តីផ្តើម

អាជីវកម្មដំណាំកាហ្វេនៅកម្ពុជាមានសក្តានុពលខ្ពស់ដោយសារតម្រូវការទីផ្សារកើនឡើងទាំងក្នុង និងក្រៅប្រទេស។ ប្រទេសកម្ពុជាមានតម្រូវការគ្រាប់កាហ្វេស្ងួតប្រមាណជា ២០,០០០ តោនក្នុងមួយឆ្នាំ តែការផលិតជាក់ស្តែងបានប្រមាណតែ ២,០០០តោន ប៉ុណ្ណោះក្នុងមួយឆ្នាំ (សមាគមកាហ្វេកម្ពុជា ២០២៥)។ ទិន្នន័យនេះបង្ហាញថា កម្ពុជាត្រូវការគ្រាប់កាហ្វេជិត ១៨,០០០ តោនក្នុងមួយឆ្នាំបន្ថែមទៀត ដែលជាឱកាសល្អសម្រាប់កសិករមានបំណងចង់ដាំដំណាំកាហ្វេ។ ការដាំដុះកាហ្វេដែលទទួលបានជោគជ័យត្រូវផ្សារភ្ជាប់ជាមួយបច្ចេកទេសនៃការដាំដុះ ការជ្រើសរើសពូជ ការរៀបចំដី ការថែទាំ និងការប្រមូលផល ព្រមទាំងកត់ត្រារាល់ការចំណាយ-ចំណូលទើបអាចកាត់បន្ថយនូវហានិភ័យនៃការខាតបង់។

## ២-ផលិតកម្មកាហ្វេ និងទីផ្សារក្នុងពិភពលោក

### ២.១- ផលិតកម្មកាហ្វេនៅក្នុងពិភពលោក

តាមរបាយការណ៍ប្រចាំឆ្នាំរបស់អង្គការកាហ្វេពិភពលោក (International Coffee Organization) បានឱ្យដឹងថាក្នុងឆ្នាំ២០២៤-២០២៥ ផលិតផលគ្រាប់កាហ្វេស្ងួតសរុបរបស់ពិភពលោកមានចំនួន ១៧៣,៤៨៣,១៤៦បាវ(១បាវ=៦០គ.ក្រ) ស្មើនឹង ១០,៤០៨,៩៨៨.៧៦តោន គឺថយចុះ ២.៦% បើធៀបនឹងឆ្នាំ២០២៣-២០២៤ ដែលមានប្រមាណ ១៧៨,០០០,០០០បាវ ស្មើនឹង ១០,៦៨០,០០០តោន។

| ប្រទេសផលិតសំខាន់ៗ | ភាគរយនៃផលិតកម្មកាហ្វេសកលលោក (%) | ផលិតកម្មកាហ្វេ (Green Bean) ឆ្នាំ២០២៤/២០២៥ គិតជាបាវ (ទំងន់៦០គីឡូក្រាម/បាវ) | បរិមាណសរុប (តោន) |
|---|---|---|---|
| ប្រេស៊ីល | 37% | 64,700,000 | 3,882,000 |
| វៀតណាម | 17% | 29,000,000 | 1,740,000 |
| កូឡុំប៊ី | 8% | 13,200,000 | 792,000 |
| ឥណ្ឌូនេស៊ី | 6% | 10,700,000 | 642,000 |
| អេត្យូពី | 6% | 10,630,000 | 637,800 |
| អ៊ូហ្គង់ដា | 4% | 6,700,000 | 402,000 |
| ឥណ្ឌា | 4% | 6,200,000 | 372,000 |
| ហុងឌុយរ៉ាស់ | 3% | 5,520,000 | 331,200 |
| ប៉េរ៉ូ | 2% | 3,880,000 | 232,800 |
| សរុប | 89% | 154,400,000 | 9,264,000 |

ប្រភព÷ អង្គការកាហ្វេអន្តរជាតិ២០២៤/២០២៥ (ICO: International Coffee Organization,2024/2025)

### ២.២- ទីផ្សារកាហ្វេក្នុងពិភពលោក

តម្លៃសន្ទស្សន៍ ICO Composite (I-CIP) ជាមធ្យម ៦.២៣ដុល្លារក្នុងមួយគីឡូក្រាម ក្នុងខែធ្នូ ឆ្នាំ ២០២៥។ ខែមករា-កុម្ភៈ ឆ្នាំ២០២៦ តម្លៃជាមធ្យមនៅចន្លោះ ៦.២៤ ទៅ ៦.៩០ដុល្លារក្នុងមួយគីឡូក្រាម (International Coffee Organization, Report-December 2025 and Report-January-February 2026)។

## ៣-ផលិតកម្មកាហ្វេនៅប្រទេសកម្ពុជា និងប្រទេសជិតខាង

### ៣.១- ផលិតកម្មកាហ្វេ នៅប្រទេសកម្ពុជា និងប្រទេសជិតខាង

តារាងខាងក្រោមនេះបង្ហាញពីផ្ទៃដីដាំដុះ ផ្ទៃដីប្រមូលផល ទិន្នផល និងបរិមាណផលនៃដំណាំកាហ្វេនៅប្រទេសកម្ពុជា វៀតណាម ឡាវ និងថៃ។ នៅកម្ពុជា ដំណាំកាហ្វេទើបតែមានការជំរុញការដាំដុះក្នុងរយៈពេលប្រមាណ៥ឆ្នាំចុងក្រោយ ដែលផ្ទៃដីបានដាំដុះនៅមានទំហំតូចនៅឡើយ។ វៀតណាមជាប្រទេសផលិតកាហ្វេទី១នៅអាស៊ី និងទី២នៅលើពិភពលោកបន្ទាប់ពីប្រទេសប្រេស៊ីល។ ឡាវជាប្រទេសផលិតកាហ្វេទី៣បន្ទាប់ពីប្រទេសវៀតណាម និងឥណ្ឌូនេស៊ី នៅអាស៊ីអាគ្នេយ៍។ តាមទិន្នន័យពីក្រសួងកសិកម្ម និងសហករណ៍ថៃ វិស័យដំណាំកាហ្វេនៅប្រទេសថៃនៅមានកម្រិតនៅឡើយ ទាំងផ្ទៃដីដាំដុះ បច្ចេកទេស និងទិន្នផល។

### ៣.២- តារាងផលិតកម្មកាហ្វេ នៅកម្ពុជា វៀតណាម ឡាវ និងថៃ

| ប្រទេស | ផ្ទៃដីដំដុះ (ហិកតា) | ផ្ទៃដីប្រមូលផល (ហិកតា) | ទិន្នផល/ ហិកតា (គ.ក្រ) | បរិមាណផល/ ឆ្នាំ (តោន) | តម្រូវការប្រចាំឆ្នាំ (តោន) |
|---|---|---|---|---|---|
| កម្ពុជា | ១,៣៥០ | ១,០០០ | ២,០០០ | ២,០០០ | ២០,០០០ |
| វៀតណាម | ៧១៥,០០០ | ៦៥៥,០០០ | ២,៦០០ | ១,៧០០,០០០ | ២៧០,០០០ |
| ឡាវ | ១១០,០០០ | ៩៥,០០០ | ១,៧៣៥ | ១៦៥,០០០ | ៦,០០០ |
| ថៃ | ៣៣,០០០ | ២៩,០០០ | ៦៥០ | ១៨,៨៥០ | ១០០,០០០ |

## ៤-ការអនុវត្តការដាំដុះ

### ៤.១-ការជ្រើសរើសទីតាំង និងដី

នៅកម្ពុជា ដំណាំកាហ្វេអាចដាំបានល្អនៅរយៈកម្ពស់ពី ១២០-២,០០០ ម៉ែត្រ។ ពូជ រ៉ូប៊ូស្តា (Robusta) អាចដាំបាននៅរយៈកម្ពស់ ១២០-១,៣០០ម៉ែត្រ និងសីតុណ្ហភាពចន្លោះពី ២២-៣២ អង្សាសេ។ ប្រភេទពូជ អារ៉ាប៊ីកា (Arabica) អាចដាំបានល្អនៅរយៈកម្ពស់ ៦០០-២,០០០ម៉ែត្រ និងសីតុណ្ហភាពត្រជាក់ប្រចាំថ្ងៃល្អបំផុត ១៥-៣០ អង្សាសេ។ កាហ្វេ Arabica និង Robusta ត្រូវការកម្រិតទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំប្រហាក់ប្រហែលគ្នា ពី ១,២០០- ១,៨០០ មីលីម៉ែត្រ ដែលរាយប៉ាយក្នុងរយៈពេល ៩ខែ។

ដំណាំកាហ្វេត្រូវការដីក្រហមភ្នំភ្លើងមានរចនាសម្ព័ន្ធ វាយនភាពល្អ សម្បូរនូវសារធាតុសរីរាង្គ និងសមាសធាតុខនិជផ្សេងៗ។ លក្ខខណ្ឌសមស្របសម្រាប់កាហ្វេគឺជាដីមានកម្រិតជាតិអាស៊ីតខ្សោយ pH ដីស្ថិតនៅចន្លោះពី ៥.៥- ៦.៥ ដីស្រស់ទឹកល្អ និងគួរជៀសវាងដីឥដ្ឋធ្ងន់ងាយជាំទឹក។

### ៤.២- ប្រព័ន្ធស្រោចស្រព

ដំណាំកាហ្វេត្រូវការទឹកគ្រប់គ្រាន់ដើម្បីលូតលាស់បានល្អចាប់តាំងពីដំណាក់កាលដាំដុះដំបូងរហូតដល់ពេលដែលវាចាក់ឫសរឹងមាំ។ វិធីសាស្ត្រស្រោចស្រពគឺអាចធ្វើតាមរយៈការប្រើដប (bottle irrigation) ប្រព័ន្ធដំណក់ (Drip Irrigation) និងប្រព័ន្ធសាច (Sprinkler Irrigation) មានប្រសិទ្ធិភាពជួយកាត់បន្ថយកម្លាំងពលកម្ម។




ការស្រោចស្រពដោយប្រើដប



ប្រព័ន្ធស្រោចស្រពដោយដំណក់ទឹក



ប្រព័ន្ធស្រោចស្រពដោយសាចទឹក

### ៤.៣- ការជ្រើសរើសពូជកាហ្វេ

៤.៣.១- អារ៉ាប៊ីកា (Arabica coffee) អាចដុះលូតលាស់រហូតដល់កម្ពស់១២ម៉ែត្រ នៅក្នុងព្រៃធម្មជាតិ មានស្លឹកពណ៌បៃតងចាស់ជារាងពងក្រពើឬរាងទ្រវែង និងមានផ្លែមានពណ៌ក្រហមឆ្អិនឆ្អៅនៅពេលទុំ ដោយមួយផ្លែមានចំនួន២គ្រាប់ មានផ្ទុកជាតិកាហ្វេអ៊ីនប្រមាណ ១.៥% និងកម្រិតជាតិស្ករ ៦-៩%។

៤.៣.២-រ៉ូប៊ូស្តា (Robusta) ជាពូជមានឫសរាក់ អាចដុះលូតលាស់បានកម្ពស់ជាមធ្យម១០ម៉ែត្រ។ ពូជកាហ្វេរ៉ូប៊ូស្តាផ្តល់ទិន្នផលខ្ពស់ជាងពូជអារ៉ាប៊ីកា ជាពូជធន់ជាមួយសត្វល្អិត និងជំងឺ ហើយមានផ្ទុកជាតិកាហ្វេអ៊ីន ២.៧% និងជាតិស្ករចន្លោះ៣-៧%។




ដើម ផ្កា គ្រាប់ កាហ្វេអារ៉ាប៊ីកា និងរ៉ូប៊ូស្តា

## ៤.៤-ការរៀបចំល្បាយដីសម្រាប់បណ្ដុះកាហ្វេ

ដីសម្រាប់បណ្ដុះកូនកាហ្វេត្រូវតែមានសារធាតុចិញ្ចឹមគ្រប់គ្រាន់ ធូរ (មិនហាប់ណែន) និងស្រស់ទឹកបានល្អ (ដីមិនបៀមទឹក)។ រូបមន្តល្បាយដីដែលគេនិយមប្រើបំផុតគឺដីមមោកស្រទាប់លើមានដីជាតិចំនួន៥០% ដីកំប៉ុស្ត ឬលាមកសត្វពុកផុយ ៣០% និងធ្យូងអង្កាមដុត ឬខ្សាច់ម៉ដ្ឋ ២០%។

**៤.៤.១-បណ្ដុះពូជដោយគ្រាប់÷** គ្រាប់ពូជអាចចាប់ផ្ដើមបណ្ដុះនៅចុងខែវិច្ឆិកា ឬដើមខែធ្នូ ដោយជ្រើសរើសសម្រាំងយកគ្រាប់ធំល្អ មិនមានប្រេះ ឬឆែប បន្ទាប់មកយកទៅត្រាំនឹងទឹកក្ដៅឧណ្ហៗរយៈពេលពី ២០ ទៅ ៣០នាទី រួចស្រង់វាចេញទុកឱ្យស្ងួតរយៈពេល៣ថ្ងៃ ហើយយកទៅសាបលើថ្នាលរយៈពេល២០ ទៅ ៦០ថ្ងៃ ដែលដុះចេញជាកូនកាហ្វេមានត្រួយ ២ ទៅ៣សន្លឹក។ នៅពេលកូនកាហ្វេមានអាយុពី ១ ទៅ ១ខែកន្លះ ដកយកទៅផ្សាំក្នុងថង់រយៈពេល ១ខែ ទៅ ២ខែ ទើបយកទៅដាំនៅចម្ការ។



កូនកាហ្វេដែលបណ្ដុះដោយគ្រាប់

៤.៤.២-ពូជកាត់បណ្តុះ÷ ការដាំដំណាំកាហ្វេតាមវិធីកាត់បណ្តុះ (Coffee Cutting) គឺជាបច្ចេកទេសពេញនិយមមួយដែលទទួលបានកូនកាហ្វេដែលមានលក្ខណៈសម្បត្តិដូចមេបាបេះបិទ និងចំណាយពេលតិចជាងការបណ្តុះដោយគ្រាប់។ ការជ្រើសរើសមែកសម្រាប់ផ្សាំត្រូវជ្រើសរើសដើមមេដែលមានសុខភាពល្អ ផ្តល់ទិន្នផលខ្ពស់ មែកដែលដុះចេញពីដើមមេត្រង់ឡើងទៅលើមានពណ៌បៃតងចាស់ ឬចាប់ផ្តើមឡើងពណ៌ត្នោតខ្ចី។ កសិករគួរជៀសវៀងជ្រើសរើសមែកដែលដុះទទឹងឬផ្តេក មែកដែលមិនខ្ចីពេក ឬចាស់ពេក ព្រោះវានឹងដុះទៅជាដើមដែលវៀច និងមិនលូតលាស់បានល្អ។ មែកពូជត្រូវកាត់ជាកង់ៗ ដែលមានជាប់ថ្នាំង ២ ទៅ ៣ ប្រវែងប្រហែល ១០-១៥ សង់ទីម៉ែត្រ ដោយកាត់ផ្នែកខាងក្រោមនៃមែកឱ្យមានរាងបញ្ឆិត ដើម្បីបង្កើនផ្ទៃសម្រាប់ដុះឫស និងកាត់ពាក់កណ្តាលនៃស្លឹក ដើម្បីកាត់បន្ថយការរំភាយចំហាយទឹក។ កសិករអាចរំញោចមែកកាត់បណ្តុះដោយអរម៉ូនជំរុញការដុះឫស (Rooting Hormone) មុនដោតចូលក្នុងថង់ដែលមានល្បាយដីបណ្តុះ ឬរោងបណ្តុះ ទុករយៈពេល ២០-៣០ថ្ងៃ ទើបដុះឫស និងកូនកាហ្វេត្រូវការពេលពី ២ ទៅ ៤ខែ ផ្សាំក្នុងថង់មុនយកទៅដាំក្នុងចម្ការ។



មែកកាហ្វេដែលត្រូវបានកាត់បណ្តុះ

## ៤.៥-វិធីដាំដុះ

៤.៥.១- ការរៀបចំរណ្តៅ÷ រណ្តៅត្រូវរៀបចំទុកជាមុនរដូវដាំដុះ ដោយបោះបង្គោលចំណាំគម្លាតដើម៣ម៉ x គម្លាតជួរ៣ម៉ ជីករណ្តៅមានអង្កត់ផ្ចិត ៦០ស.ម និងជម្រៅ ៦០ស.ម ដោយត្រូវការកូនកាហ្វេប្រមាណ ១១០០ ដើមក្នុងមួយហិកតា។ ការដាំកាហ្វេអាចចាប់ផ្តើមនៅដើមរដូវភ្លៀង(ឧសភា-មិថុនា)។ ចំពោះផ្ទៃដីដែលមានចំណោត កសិករត្រូវកាប់ដីស្រទាប់លើនៅផ្នែកខាងលើនៃចំណោត ដើម្បីឱ្យដីនោះហូរចូលក្នុងរណ្តៅមុនគេប្រសិនបើមានភ្លៀងធ្លាក់មុនពេលលុបរណ្តៅ ចំណែកដីស្រទាប់ក្រោម ត្រូវដាក់នៅផ្នែកខាងក្រោមនៃរណ្តៅ ដើម្បីការពារកុំឱ្យវាហូរចូលទៅក្នុងរណ្តៅវិញ។






ការជីក ឬខ្ទងរណ្តៅ

**៤.៥.២-លក្ខណៈកូនកាហ្វេ÷**នៅដើមរដូវវស្សា ត្រូវជ្រើសរើសកូនកាហ្វេដែលដុះចេញនូវស្លឹកពិត (True leaves) ចំនួន ៣ ទៅ ៤គូ សម្រាប់ការផ្សាំមែក (Clonal cuttings) ឬ ៤ ទៅ ៥ គូ សម្រាប់កូនកាហ្វេដែលបណ្តុះចេញពីគ្រាប់ពូជជម្រើស។ កសិករត្រូវប្រើប្រាស់កូនកាហ្វេចេញពីកន្លែងបណ្តុះដែលគ្មានការបំផ្លាញពីសត្វល្អិត និងជំងឺ ដូចជាចៃម្សៅនៅឫស (Root mealybugs) ចៃលើស្លឹក (Aphids) សត្វល្អិតបឺតជញ្ជក់ និងជំងឺអុចភ្នែកមាន់ (Brown eye leaf spot)។ ការធ្វើបែបនេះគឺដើម្បីបង្ការការនាំចូលសត្វល្អិត និងជំងឺទៅក្នុងចម្ការកាហ្វេ។ កូនកាហ្វេដែលល្អគឺមិនមានដុះឫសលយចេញមកក្រៅថង់ប្លាស្ទិកវែងពេក ឬឫសកែវកោង (ទម្រង់ឫសអក្សរ J)។

**៤.៥.៣-ការដាក់កូនដាំ÷** ត្រូវប្រើធុងទឹក ឬអាងទឹក ដើម្បីត្រាំកូនកាហ្វេឱ្យបានជោគទឹកល្អ បន្ទាប់មកយកថង់កូនបណ្តុះមកកាត់ឫសចាស់ឬឫសដុះលយចេញពីថងឱ្យអស់ និងកាត់ថង់ប្លាស្ទិកចេញទើបដាក់ដាំក្នុងរណ្តៅ ហើយលុបដីមានជីជាតិជម្រៅប្រហែល ២០ សង់ទីម៉ែត្រ ជាមួយដីស្រទាប់លើជាមួយជីកំប៉ុស្ត ឬជីលាមកសត្វដែលពុកផុយល្អចំនួន ៥-១០គីឡូក្រាមក្នុងរណ្តៅ។ ការលុបដីត្រូវកៀរឱ្យបានស្មើទៅនឹងដីកំណើតរបស់កូនកាហ្វេដើម្បីការពារការជាំទឹក ឬកើតនូវជំងឺនៅគល់កូនកាហ្វេ។






កូនកាហ្វេត្រៀមយកទៅដាំ

## ៥-ការថែទាំ

### ៥.១- ការស្រោចទឹក

ដំណាំកាហ្វេត្រូវការទឹកគ្រប់គ្រាន់ចាប់តាំងពីដំណាក់កាលដាំដុះដំបូងរហូតដល់ពេលដែលដើមកាហ្វេចាក់ឫសរឹងមាំល្អ និងបន្តស្រោចជាប្រចាំតាមភាពជាក់ស្តែង។ ការស្រោចស្រពទឹកដើមកាហ្វេអាចធ្វើឡើង៣ដងក្នុងមួយសប្តាហ៍នៅរដូវប្រាំង និងម្តងម្កាលនៅរដូវភ្លៀងធ្លាក់អាស្រ័យទៅនឹងសំណើមដីជាក់ស្តែង កម្រិតសម្ងួតប្រចាំថ្ងៃ វាយនភាពរបស់ដី និងទំហំដើមកាហ្វេ។ ខាងក្រោមនេះជាបរិមាណនៃការស្រោចស្រពដំណាំកាហ្វេទៅតាមអាយុកាល÷

| អាយុកាល | ការស្រោចស្រព |
|---|---|
| កាហ្វេអាយុក្រោម៦ខែ | ស្រោចម្តង២លីត្រក្នុង១ដើម និង៣ដងក្នុង១សប្តាហ៍ |
| កាហ្វេអាយុ១ឆ្នាំ | ស្រោចម្តង៣លីត្រក្នុង១ដើម និង៣ដងក្នុង១សប្តាហ៍ |
| កាហ្វេអាយុ២ឆ្នាំ | ស្រោចម្តង៥លីត្រក្នុង១ដើម និង៣ដងក្នុង១សប្តាហ៍ |
| កាហ្វេអាយុ៣ឆ្នាំ | ស្រោចម្តង៧លីត្រក្នុង១ដើម និង៣ដងក្នុង១សប្តាហ៍ |
| កាហ្វេអាយុអាយុ៤ឆ្នាំ | ស្រោចម្តង១០លីត្រក្នុង១ដើម និង៣ដងក្នុង១សប្តាហ៍ |
| កាហ្វេអាយុ៥ឆ្នាំឡើង | ស្រោចម្តង១២លីត្រក្នុង១ដើម និង៣ដងក្នុង១សប្តាហ៍ |

ការស្រោចស្រពអាចប្រែប្រួលតាមស្ថានភាពជាក់ស្តែង

### ៥.២- សារធាតុចិញ្ចឹម និងការដាក់ជីដំណាំកាហ្វេ

**៥.២.១- សារធាតុចិញ្ចឹម÷** ដើម្បីធានាថាដំណាំកាហ្វេទទួលបានពីសារធាតុចិញ្ចឹមសំខាន់ៗ រួមមាន អាសូត (N) ផូស្វ័រ (P) និង ប៉ូតាស្យូម(K) និងសារធាតុចិញ្ចឹមតូចៗជាច្រើនទៀតរួមមាន ស័ង្កសី(Zinc) បរ (Boron) ដែក (Iron) ស្ពាន់ធ័រ (Sulphur) ម៉ាញេស្យូម (Magnesium) កាល់ស្យូម (Calcium) ទង់ដែង (Copper) ម៉ង់កាណែស (Manganese) ម៉ូលីបដែន (Molybdenum) និងក្លរ (Chlorine)។ សារធាតុចិញ្ចឹមទាំងនេះ បានចូលរួមយ៉ាងសកម្មក្នុងធ្វើឱ្យមានតុល្យភាពវដ្ដជីវិតរបស់កាហ្វេដូចជា ការលូតលាស់ ភាពធន់នឹងសត្វល្អិត-ជំងឺ ភាពធន់នឹងអាកាសធាតុ និងជំរុញទិន្នផលគ្រាប់កាហ្វេផងដែរ។

**៥.២.២-ជីធម្មជាតិ ឬជីសរីរាង្គ÷**មានប្រភពមកពីសារធាតុសរីរាង្គដូចជា លាមកសត្វ( លាមកគោ លាមកមាន់ ចៀម ពពែ) កំប៉ុសដែលបានមកពីសំណល់ផ្ទះបាយ និងកម្ទេចកម្ទីរុក្ខជាតិ( ស្លឹកឈើ កម្ទេចស្មៅ កាកសំណល់បន្លែ-ផ្លែឈើ)។ ការប្រើប្រាស់ជីកំប៉ុស ឬលាមកសត្វដែលបំបែកល្អ ជួយបន្ថែមសារធាតុសរីរាង្គទៅក្នុងដី កែលម្អរចនាសម្ព័ន្ធរូបវន្តគីមី និងជីវសាស្ត្ររបស់ដីកាន់តែប្រសើរឡើង ហើយអាចកាត់បន្ថយការពឹងផ្អែកលើផលិតផលជីគីមីដែលមានតម្លៃថ្លៃនៅលើទីផ្សារ។

**៥.២.៣-ជីគីមី ឬជីអសរីរាង្គ÷** គឺជីដែលរុក្ខជាតិអាចស្រូបសារធាតុចិញ្ចឹមបានលឿនក្រោយពីការដាក់ទៅក្នុងដីមានសំណើមសមស្រម និងកម្រិត pH ដីសមស្រម។ ទោះជាយ៉ាងណាក៏ដោយ ជីប្រភេទនេះ

ងាយប៉ះពាល់សារពាង្គកាយអតិសុខុមប្រាណដែលជួយបំបែកសារធាតុសរីរាង្គ និងនាំឱ្យដីងាយរឹងក្លាំងកាលណាប្រើប្រាស់ហួសកម្រិត។

៥.២.៤-ការដាក់ជីដំណាំកាហ្វេ÷ នេះជាតារាងបង្ហាញពីការដាក់ជីលើដំណាំកាហ្វេទៅតាមអាយុកាល

| អាយុកាល | ប្រភេទជី | កម្រិតប្រើ/ដើម/រណ្ដៅ/ឆ្នាំ | ចំនួនដង/ឆ្នាំ | សំគាល់ |
|---|---|---|---|---|
| កូនក្នុងថ្នាល | កំប៉ុស | ១០០ក្រាម | | រាល់២ខែម្ដង |
| | គីមី (១៥-១៥-១៥) | ៥- ១០ក្រាម | | រាល់២ខែម្ដង |
| អាយុ១ឆ្នាំ | កំប៉ុស | ១,០០០ក្រាម | | ទ្រាប់បាតមុនដាំ |
| | គីមី (១៥-១៥-១៥) | ៥០ក្រាម | | ទ្រាប់បាតមុនដាំ |
| | កំប៉ុស | ៥,០០០ក្រាម | ១ | ២-៣ ខែក្រោយដាំ |
| | គីមី (២០-១០-១០) | ១៥០ -២០០ក្រាម | ១ | ២-៣ខែក្រោយដាំ កញ្ញា-តុលា |
| អាយុ២ឆ្នាំ | កំប៉ុស | ៥,០០០ក្រាម | ១ | ឧសភា-មិថុនា |
| | គីមី (១៦-១៦-១៦) | ២៥០-៣០០ក្រាម | ២ | ឧសភា-មិថុនា និងកញ្ញា-តុលា ក្នុងរដូវភ្លៀង |
| អាយុ៣ឆ្នាំ | កំប៉ុស | ១០គ.ក្រ | ១ | ឧសភា-មិថុនានៅដើមរដូវភ្លៀង |
| | គីមី (១៦-១៦-១៦) | ៤០០-៥០០ក្រាម | ២ | ឧសភា-មិថុនា) និង (កញ្ញា-តុលា) ដើមនិងចុងរដូវភ្លៀង |
| ៤-៥ឆ្នាំឡើងទៅ | កំប៉ុស | ១០គ.ក្រ | ១ | ឧសភា-មិថុនា នៅដើមរដូវភ្លៀង |
| | គីមី (១៦-១៦-១៦ + អ៊ុយរ៉េ ១០០-១៥០ក្រាម) | ៦០០-៨០០ក្រាម | ២ | ឧសភា-មិថុនា និងកញ្ញា-តុលា នៅដើមនិងចុងរដូវភ្លៀង |

បញ្ជាក់÷ កសិករត្រូវវិភាគដី និងស្លឹកកាហ្វេនៅមន្ទីរពិសោធន៍ ដើម្បីអាចដាក់ជីឱ្យសមស្របតាមតម្រូវការរបស់កាហ្វេ និងកម្រិតសារធាតុចិញ្ចឹមក្នុងដីនៃចម្ការ។ ម្យ៉ាងទៀតកសិករអាចពិនិត្យមើលលើការលូតលាស់ ពណ៌ស្លឹកកាហ្វេ ដែលអាចបង្ហាញពីតម្រូវការជាក់ស្ដែង ឬពិភាក្សាជាមួយអ្នកជំនាញ។ ការដាក់ជីបរិមាណច្រើនតែម្ដងក្នុងមួយឆ្នាំ អាចបង្កើនអត្រាបាត់បង់ជីតាមទឹកហូរ (ការហូរច្រោះ) រំភាយសារធាតុជី និងរុក្ខជាតិមិនអាចស្រូបជីជាតិអស់ពីលទ្ធភាព។ ជាការអនុវត្តឱ្យបានប្រសើរ គួរដាក់ជីគីមីរាល់២ខែម្ដង និងជីកំប៉ុសរាល់៤ខែម្ដងឬ១ឆ្នាំម្ដងយ៉ាងតិចដើម្បីរក្សាលំនឹងដើម និងទិន្នផលបន្តបន្ទាប់។




សារធាតុចិញ្ចឹមដំណាំកាហ្វេ

## ៥.៣- ការតាក់តែងមែក (Pruning) និងការកាត់ដើម (Stumping)

**៥.៣.១- ការកាត់តែងមែក (Pruning) ÷** គឺជាការកាត់យកចេញនូវមែកបាក់ ងាប់ គ្មានទិន្នផល មែកចាស់ខ្លាំងកើតជំងឺ និងមែកដែលរងការបំផ្លាញដោយសត្វល្អិត។ វាគឺជាកិច្ចការដ៏សំខាន់ចាំបាច់ ដើម្បីរក្សាដើមកាហ្វេឱ្យមានសុខភាពល្អ រឹងមាំ ធ្វើឱ្យការស្រូបជីមានប្រសិទ្ធភាព ដែលនាំឱ្យផ្តល់ទិន្នផលផ្លែកាហ្វេបានខ្ពស់ពេញមួយវដ្តនៃផលិតកម្ម និងជួយកាត់បន្ថយការប្រើប្រាស់ធាតុចូលកសិកម្ម ដូចជាជី ឬថ្នាំកសិកម្មជាដើម។

**៥.៣.២- ការកាត់ដើម(Stumping) ÷** ការកាត់ដើមត្រឹមគល់អាចធ្វើបានចំពោះដើមកាហ្វេដែលចាស់ខ្លាំង ឬដើមអន់ថយទិន្នផលដែលមានអាយុលើសពី ៧ ដល់ ១០ឆ្នាំ។ កាត់ដើមមេឱ្យនៅសល់គល់កម្ពស់ប្រហែល ៣០ ទៅ ៥០ សង់ទីម៉ែត្រពីដី។ នៅពេលដើមកាហ្វេដុះកូនពន្លកថ្មីចេញពីគល់ ត្រូវជ្រើសរើសយកតែ ១-២ ពន្លកដែលមាំជាងគេទុកធ្វើជាដើមមេថ្មី ហើយកាត់ចោលនូវពន្លកដែលដុះផ្សេងទៀត។



ការតាក់តែងមែក និងការកាត់ដើម

## ៥.៤- ការគ្រប់គ្រងស្មៅ

ស្មៅគឺជាប្រភេទរុក្ខជាតិទាំងឡាយណាដែលយើងមិនចង់ឱ្យដុះនៅក្នុងចម្ការកាហ្វេមុនពេលកាហ្វេចេញផ្កា និងមុនពេលដាក់ជី។ ស្មៅប្រជែងដណ្ដើមស្រូបទឹក និងសារធាតុចិញ្ចឹមជាមួយដើមកាហ្វេដែលធ្វើឱ្យកាហ្វេលូតលាស់យឺត ទិន្នផលទាប គុណភាពគ្រាប់កាហ្វេមិនល្អ។ នៅពេលចុងរដូវវស្សាត្រូវសម្អាតស្មៅឱ្យបានស្អាតពីជុំវិញដើមកាហ្វេរហូតដល់ដើមរដូវវស្សាបន្ទាប់។ វិធីសាស្ត្រមូលដ្ឋានចំនួន ៣ ដើម្បីគ្រប់គ្រងស្មៅរួមមាន៖ តាមបែបវប្បកម្ម (ប្រើកម្លាំងមនុស្ស) តាមបែបមេកានិច (ម៉ាស៊ីនកាត់) និងតាមបែបគីមី (ថ្នាំកម្ចាត់ស្មៅ)តែមិនត្រូវបាញ់ប៉ះនឹងស្លឹក និងដើមកាហ្វេ (ប្រើរបាំងការពារពេលបាញ់)។

## ៥.៥- សត្វល្អិតបំផ្លាញ

**៥.៥.១-ចៃម្សៅ៖** ចៃម្សៅកាហ្វេ (Coffee mealybugs - អំបូរ *Planococcus*) គឺជាសត្វល្អិតបឺតជញ្ជក់ (មានប្រវែងប្រហែល ៣ មីលីម៉ែត្រ) ដែលច្រើនរាតត្បាតខ្លាំងនៅរដូវប្រាំង មិនមានទឹកស្រោចស្រពគ្រប់គ្រាន់។ ចៃម្សៅបឺតជញ្ជក់យករុក្ខរសជាអាហារចេញពីស្លឹក ត្រួយខ្ចី ត្របកផ្កា ផ្លែកាហ្វេខ្ចី និងទុំ ព្រមទាំងឫសផងដែរ ដែលបណ្ដាលឱ្យស្លឹកមានសភាពលឿង និងជ្រុះ។ វិធានការ៖ កសិករក៏អាចប្រើប្រាស់**ប្រេង** ដូចជា ប្រេងស្ដៅ (Neem oil) ឬ**ស្វូលុយស្យុងទឹកសាប៊ូ** (ពី ១ ទៅ ២%) ដើម្បីសម្លាប់ចៃម្សៅដោយធ្វើឱ្យវាថប់ដង្ហើម។ ការប្រើប្រាស់ទឹកសាប៊ូ ឬប្រេង គួរធ្វើឡើងនៅពេលអាកាសធាតុត្រជាក់ និងគ្មានពន្លឺថ្ងៃខ្លាំង ដើម្បីការពារកុំឱ្យខូចពណ៌ស្លឹក។ ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតដូចជា Chlorpyrifos, Sumithion និង Carbaryl ។

**៥.៥.២-ចៃក្រមួន (Scales)៖** គឺជាសត្វល្អិតចង្រៃម្យ៉ាងទៀតដែលស្រដៀងនឹងចៃម្សៅដែរ ប៉ុន្តែពួកវាមានលក្ខណៈខុសគ្នាមួយចំនួនដូចជា ចៃក្រមួនមានរាងមូល ឬទ្រវែង ហើយមានស្រទាប់រឹង (ដូចសំបក) គ្របដណ្ដប់ពីលើខ្នង។ ពពួកនេះនៅជាប់នឹងមែក ស្លឹក ឬផ្លែ ដើម្បីបឺតជញ្ជក់យកជាតិរុក្ខរសពីកាហ្វេ នាំឱ្យបន្ថយការលូតលាស់ស្លឹក ត្រួយ និងផ្លែ។ វិធានការ៖ ប្រេងស្ដៅ (Neem oil) ២ ស្លាបព្រាបាយ + ទឹកសាប៊ូលាងចាន ១ ស្លាបព្រាបាយ + ទឹកស្អាត ១ លីត្រ។ បាញ់ឱ្យជោកនៅផ្នែកខាងក្រោមស្លឹក និងតាមខ្នែងមែក។ ហាមបាញ់នៅពេលថ្ងៃត្រង់ដែលមានកម្ដៅថ្ងៃខ្លាំង ព្រោះវាអាចធ្វើឱ្យឆេះស្លឹកកាហ្វេ។ គួរបាញ់នៅពេលព្រឹកព្រលឹម ឬពេលល្ងាចត្រជាក់។ ការប្រើប្រាស់ថ្នាំកសិកម្ម (ករណីរាតត្បាតខ្លាំង) កសិករអាចជ្រើសរើសប្រភេទថ្នាំដែលជ្រាបចូលក្នុងសរសៃរុក្ខជាតិ (Systemic Insecticide) ដែលមានសារធាតុ Imidacloprid ឬ Thiamethoxam ។

**៥.៥.៣-ពពួកចៃអាហ្វីដ (Aphids)៖** ជាសត្វល្អិតតូចៗដែលមានដងខ្លួនទន់ ពណ៌ខ្មៅ ឬត្នោតចាស់ ដែលច្រើនតែរស់នៅជាហ្វូងតាមត្រួយខ្ចី ក្រោមស្លឹក និងទងផ្កាកាហ្វេ។ ពួកវាបឺតជញ្ជក់ជ័ររុក្ខជាតិដែលបណ្ដាលឱ្យស្លឹកកាហ្វេរួញ និងលូតលាស់យឺត។ វិធានការ៖ ប្រសិនបើមានចៃតិចតួចលើដើមតូចៗ កសិករអាចប្រើក្បាលបាញ់ទឹកដែលមានសម្ពាធខ្លាំង បាញ់កម្ចាត់ពួកវាឱ្យធ្លាក់ពីលើស្លឹក។ ពួកវាមិន

ងាយនឹងឡើងមកលើដើមវិញបានទេ។ ប្រើសត្វល្អិតក្រហម (Ladybugs) និងសត្វល្អិត Lacewings គឺជាអ្នកស៊ីចៃ(Aphids)។ សិនបើការរាតត្បាតកើតឡើងខ្លាំងពេញចម្ការ កសិករអាចប្រើថ្នាំដែលមានសារធាតុសកម្មដូចជា Abamectin ឬ Alpha-cypermethrin និងត្រូវបាញ់នៅផ្នែកខាងក្រោមស្លឹក និងតាមត្រួយខ្ចីឱ្យសព្វ ព្រោះចៃអង្គ្រងចូលចិត្តពួននៅទីនោះ។

**៥.៥.៤- ដង្កូវស៊ីរូងដើម (Coffee stem borer)÷** សត្វល្អិតទម្លុះដើមពីរប្រភេទគឺ÷ ដង្កូវស៊ីដើមក្បាលស និង ដង្កូវស៊ីដើមក្បាលលឿង។ ដង្កូវស៊ីដើមក្បាលស (White stem borer - ឈ្មោះវិទ្យាសាស្ត្រ Bixadus sierricola) រាតត្បាតខ្លាំងជាពិសេសលើកាហ្វេប្រភេទ Arabica ជាង Robusta។ **វិធានការ÷** ដង្កូវស៊ីដើមក៏អាចគ្រប់គ្រងបានតាមបែបបច្ចេកទេសកសិកម្ម ដោយការប្រើធ្នាប់កង់ ឬសរសៃលួស រុកចូលទៅក្នុងរន្ធដើម្បីចាក់សម្លាប់ដង្កូវ។ កសិករអាចប្រើប្រាស់សំឡីជ្រលក់ជាមួយថ្នាំ Fenitrothion ឬ Cypermethrin រួចញាត់ចូលទៅក្នុងរន្ធដែលវាចោះ ដើម្បីសម្លាប់ដង្កូវខ្ទងនៅខាងក្នុង។

**៥.៥.៥- ខ្ទួតចោះស៊ីផ្លែ (Coffee Berry Borer)÷** មានឈ្មោះវិទ្យាសាស្ត្រថា *Hypothenemus hampei (Ferrari)* គឺជាសត្វល្អិតចង្រៃបំផុតមួយក្នុងចំណោមសត្វល្អិតបំផ្លាញកាហ្វេប្រភេទ Arabica ដែលបង្កការខូចខាត និងធ្វើឱ្យបាត់បង់ទិន្នផលចន្លោះពី ៥០% ទៅ ១០០%។ **វិធានការ÷** ការកាត់តម្រឹមមែកកាហ្វេ និងដើមឈើផ្តល់ម្លប់ ដើម្បីបើកពន្លឺឱ្យសត្រូវធម្មជាតិអាចមើលឃើញ និងស៊ីសត្វល្អិតប្រភេទនេះ។ បេះផ្លែទុំឱ្យទាន់ពេលវេលា កប់ផ្លែជ្រុះទៅក្នុងដី និងដុតផ្លែដែលរងការបំផ្លាញ។ បាញ់ថ្នាំនៅដំណាក់កាលផ្លែកាហ្វេនៅតូចដោយប្រើCypermetrin, Deltametrin, Pyrethroids ឬ Chlorpyrifos តាមកម្រិតដែលបានណែនាំនៅលើស្លាកសញ្ញា។

**៥.៥.៦- ខ្ទុងស៊ីស្លឹក÷**ជាប្រភេទសត្វល្អិតស្លាបរឹងដែលស៊ីបំផ្លាញស្លឹកត្រួយកាហ្វេនៅពេលយប់។ **វិធានការ÷** ប្រើថ្នាំ Chlorpyrifos, Cypermetrin និង Imidacloprid ដោយបាញ់នៅពេលល្ងាច និងពេលព្រលប់ទើបមានប្រសិទ្ធភាពព្រោះជាពេលចេញស៊ីបំផ្លាញខ្លាំង។



សត្វល្អិតចៃស ឬចៃម្សៅ



ចៃក្រមួន



ចៃអាហ្វីដ



ខ្មូតចោះស៊ីផ្លែ និងគ្រាប់ | ដួងស៊ីដើម និងមេពេញវ័យ | ខ្មុងស៊ីស្លឹកកាហ្វេ

## ៥.៦- ប្រភេទជំងឺ

**៥.៦.១- ជំងឺក្រៀមស្វិតកាហ្វេ (Coffee Wilt Disease - CWD)** ÷ ជំងឺនេះត្រូវបានគេស្គាល់ថាជា "ជំងឺផ្សិត Fusarium" ឬ "Tracheomycosis spp" គឺបង្កឡើងដោយពពួកផ្សិត *Fusarium xylarioides* ឬ *Gibberella xylarioides* ហើយវាត្រូវបានគេចាត់ទុកថាជាការគំរាមកំហែងផ្នែកជីវសាស្ត្រដ៏សំខាន់បំផុតចំពោះការផលិតកាហ្វេ។ ពពួកផ្សិតនេះវាយប្រហារទៅលើសារធាតុចិញ្ចឹមពីឫសទៅកាន់ផ្នែកផ្សេងៗទៀតរបស់ដើមកាហ្វេដែលបណ្ដាលឱ្យរាំងស្ទះការលូតលាស់។ការរាំងស្ទះនេះបណ្ដាលឱ្យរុក្ខជាតិក្រៀមស្វិត និងឈានទៅដល់ការងាប់ក្នុងពេលបន្ទាប់។ វិធានការ÷ ការគ្រប់គ្រងដ៏មានប្រសិទ្ធភាពបំផុតគឺចាប់ផ្ដើមឡើងដោយការប្រើប្រាស់ពូជកាហ្វេដែលមានគុណភាពល្អ ដែលបានទិញពីកន្លែងបណ្ដុះកូនកាហ្វេដែលមានទំនុកចិត្ត។ ចំពោះដើមកាហ្វេដែលត្រូវបានរងការវាយប្រហារដោយជំងឺនេះ ត្រូវតែបំផ្លាញចោល ហើយមិនត្រូវអូសកាត់ដើមដែលល្អ (គ្មានជំងឺ) នោះទេ ព្រោះអាចនឹងធ្វើឱ្យជំងឺរីករាលដាលកាន់តែខ្លាំង។

**៥.៦.២- ជំងឺច្រែះស្លឹកកាហ្វេ (Coffee leaf rust)** ÷ គឺជាជំងឺស្លឹកដែលបង្កឡើងដោយពពួកផ្សិត *Hemileia vastatrix* ដែលរាតត្បាតខ្លាំងជាងគេលើពូជកាហ្វេរ៉ូប៊ូស្តា។ រោគសញ្ញាដំបូងៗ គឺលេចឡើងនូវស្នាមអុចៗពណ៌លឿងស្លេក ដោយបន្តរីកធំស្នាមអុចពណ៌ទឹកក្រូច(ពណ៌ច្រែះ) និងប្រែជាដំបៅដែលមានពណ៌ត្នោត នៅផ្ទៃខាងក្រោមស្លឹក ដែលបណ្ដាលឱ្យស្លឹកជ្រុះមុនអាយុកាល និងកាត់បន្ថយទិន្នផល។ វិធានការ÷ អាចប្រើប្រាស់ផ្សិតល្អ ដូចជា *Lecanicillium lecanii* ឬ *Trichoderma* ដើម្បីកម្ចាត់ផ្សិតច្រែះ ហើយមានសុវត្ថិភាពចំពោះបរិស្ថាន និងសាកសមសម្រាប់កសិកម្មបែបធម្មជាតិ។ កសិករអាចប្រើថ្នាំមានសារធាតុស្ពាន់ (Copper-based fungicides) នេះជាវិធីសាស្ត្រស្តង់ដារបំផុត។ វាជួយការពារមិនឱ្យស្ព័រផ្សិតដុះលើស្លឹក។ គួរប្រើថ្នាំដែលមានសារធាតុ *Copper Oxychloride* ឬ *Copper Hydroxide*។

៥.៦.៣-ជំងឺពងបែកក្រហម (Red blister disease)÷ ដែលបង្កដោយផ្សិត Cercospora caffeicola គឺជាជំងឺផ្លែកាហ្វេដ៏ធ្ងន់ធ្ងរ និងរីករាលដាលយ៉ាងខ្លាំងលើកាហ្វេប្រភេទ រ៉ូប៊ូស្តា និង អារ៉ាប៊ីកា (Arabica) ដែលដាំដុះក្នុងតំបន់ដីរយៈកម្ពស់ទាប ដែលធ្វើឱ្យមានស្នាមអុចៗពណ៌ក្រហមតូចៗ និងហើមប៉ោងបន្តិចនៅលើផ្លែកាហ្វេពណ៌បៃតង និងផ្លែដែលជិតទុំ ស្នាមអុចទាំងនោះរីកធំទៅៗ និងភ្ជាប់គ្នាបង្កើតជាពងបែកពណ៌ក្រហម បង្កឱ្យផ្លែកាហ្វេស្ងួត មិនអាចកិនយកសំបកចេញពីគ្រាប់បានត្រឹមត្រូវឡើយ។ វិធានការ÷ ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពគឺការប្រើប្រាស់ពូជដែលធន់នឹងជំងឺ និងការប្រើជីជាតិឱ្យមានតុល្យភាពល្អ ដោយការបន្ថែមជី NPK និងជីសរីរាង្គ។ កសិករត្រូវរក្សាការកាត់តម្រឹមមែកឱ្យបានត្រឹមត្រូវ រក្សាគម្លាតដាំដុះឱ្យបានសមស្រប និងកម្ទេចសំណល់កាហ្វេដែលឆ្លងជំងឺចោល។ ប្រសិនបើដាំដុះកាហ្វេក្រោមម្លប់ (យ៉ាងហោចណាស់មានម្លប់គ្របដណ្តប់ ៥០%) ដើម្បីបង្អាក់ការកើតមានជំងឺនេះ។ ត្រូវធានាឱ្យមានប្រព័ន្ធបង្ហូរទឹកឱ្យបានល្អ។



ជំងឺក្រៀមស្វិតកាហ្វេ



ជំងឺច្រែះស្លឹកកាហ្វេ



ជំងឺពងបែកក្រហមលើផ្លែ

## ៦- ការប្រមូលផល

### ៦.១-ការផ្តល់ផល និងការប្រមូលផល

កាហ្វេអាចប្រមូលផលចាប់ពីឆ្នាំទី៣ រហូតដល់២០ឆ្នាំ។ រដូវកាលប្រមូលផលកាហ្វេគឺចាប់ពីខែតុលា និងប្រមូលឱ្យអស់ក្នុងខែធ្នូ កាលណាទុកហួសរដូវប្រមូលផល កាហ្វេនឹងរងការបំផ្លាញពីដង្កូវឬខូត។ ចាប់ពីផ្ការហូតដល់ផ្លែទុំប្រមូលផល សម្រាប់ពូជកាហ្វេអារ៉ាប៊ីកា (Arabica) ប្រើរយៈពេលចន្លោះពី ៧ ទៅ ៨ខែ ចំណែកឯកាហ្វេរ៉ូប៊ូស្តា (Robusta) ប្រើរយៈពេលយូរជាង គឺចន្លោះពី ៩ ទៅ ១១ ខែ។

គ្រាប់កាហ្វេដែលមានគុណភាពល្អបំផុតគឺទទួលបានពី "ការសម្រាំងបេះតែផ្លែទុំពណ៌ក្រហម" ផ្លែខ្ចីពណ៌បៃតងត្រូវទុកឱ្យទុំបន្តនៅ ៦ ទៅ ៨ ថ្ងៃបន្ទាប់មក។




ផ្លែកាហ្វេទុំស្រស់ដែលអាចប្រមូលផលបាន និងហាលសម្ងួតគ្រាប់កាហ្វេ (Green Bean)

## ៦.២- តារាងទិន្នផល

តារាងបង្ហាញពីទិន្នផលផ្លែទុំស្រស់ និងគ្រាប់ស្ងួត÷

| **អាយុកាលដើមកាហ្វេ** | **កម្រិតទិន្នផលផ្លែស្រស់** (ទាប-ខ្ពស់) គ.ក្រ/ហិកតា | **ទិន្នផលផ្លែស្រស់ជាមធ្យម/ហិកតា** (គ.ក្រ) | **ផ្លែស្រស់-គ្រាប់ស្ងួត** (១គ.ក្រ នៃផ្លែស្រស់ = ០.២៧ គ.ក្រ នៃគ្រាប់ស្ងួត) |
|---|---|---|---|
| ឆ្នាំទី ៣ (ចាប់ផ្តើមផ្តល់ផល) | 5,000 – 6,000 | 5,500 | 1,485 |
| ឆ្នាំទី ៤ (ផលកើនឡើង) | 7,200- 8,200 | 7,700 | 2,079 |
| ឆ្នាំទី ៥ (ផលបន្តកើន) | 10,000- 12,000 | 11,000 | 2,970 |
| ឆ្នាំទី ៦ (ផលពេញលេញ) | 12,200 – 14,200 | 13,200 | 3,564 |

## ៧-ការវិភាគសេដ្ឋកិច្ច

៧.១- តារាងវិភាគសេដ្ឋកិច្ចត្រឹមលក់ផ្លែស្រស់នៃកាហ្វេរ៉ូប៊ូស្តា (Robusta) ដែលត្រូវបានដាំដុះភាគច្រើនដោយកសិករកម្ពុជា ចាប់ផ្តើមពីឆ្នាំដំបូងដល់ឆ្នាំទី៦ លើផ្ទៃដី ១ហិកតា÷

| បរិយាយ | ឯកតា | បរិមាណ | តម្លៃ/ឯកតា (រៀល) | តម្លៃសរុប (រៀល) | ចំនួនសាររំលស់ (រៀល) | ការចំណាយក្រោយរំលស់ (រៀល) |
|---|---|---|---|---|---|---|
| **I- ចំណាយដាំដុះដំបូង (I.ក+I.ខ+I.គ)** | | | | **13,570,625** | | **4,770,625** |
| **I.ក- ការចំណាយក្នុងបណ្តុះកូនកាហ្វេ** | | | | **370,625** | | **370,625** |
| កម្លាំងពលកម្មបណ្តុះ | នាក់ | 2 | 30,000 | 60,000 | | 60,000 |
| ដាក់ជីក្នុងថ្នាលបណ្តុះ (ជីកំប៉ុស្ត) | គ.ក | 110 | 1000 | 110,000 | | 110,000 |
| ជីបំប៉នការលូតលាស់ ( ជី NPK ) | គ.ក | 8.25 | 2500 | 20,625 | | 20,625 |
| ថង់បណ្តុះ | គ.ក | 5 | 14,000 | 70,000 | | 70,000 |
| ជីលាយដីដាក់ថង់ផ្សាំកូន | នាក់ | 2 | 25,000 | 50,000 | | 50,000 |
| គ្រាប់ពូជ | គ.ក | 1 | 60,000 | 60,000 | | 60,000 |
| **I.ខ- ចំណាយសម្អាតចម្ការ** | | | | **4,400,000** | | **4,400,000** |
| ការសម្អាតដីចម្ការ | ហ.ត | 1 | 800,000 | 800,000 | | 800,000 |
| ឈ្នួលភ្ជួរដី | ហ.ត | 2 | 150,000 | 300,000 | | 300,000 |
| ឈ្នួលជីករណ្តៅ ទ្រាប់បាត និងដាំ | រណ្តៅ | 1,100 | 3,000 | 3,300,000 | | 3,300,000 |
| **I.គ- ចំណាយរៀបប្រព័ន្ធទឹក (ចំណាយមិនប្រែប្រួល)** | | | | **8,800,000** | | |
| ចំណាយលើការរំលស់ការរៀបចំប្រព័ន្ធទឹកស្រោចស្រព | ឈុត | 1 | 8,000,000 | 8,000,000 | | |
| ចំណាយលើការរំលស់ប្រព័ន្ធលាយជីទឹកតាមទុយោដំណក់ | ឈុត | 1 | 800,000 | 800,000 | | |
| **II.-ចំណាយថែទាំឆ្នាំទី១** | | | | **8,573,000** | | **10,039,667** |
| កម្លាំងពលកម្ម | ឆ្នាំ | 1 | 1,000,000 | 1,000,000 | | 1,000,000 |
| ឈ្នួលជម្រះស្មៅក្រោយដាំ | ដង | 3 | 300,000 | 900,000 | | 900,000 |
| ជីបំប៉នការលូតលាស់ (ជីសរីរាង្គ) | គ.ក្រ | 5,500 | 1,000 | 5,500,000 | | 5,500,000 |
| ជីបំប៉នការលូតលាស់ (ជី NPK) | គ.ក្រ | 110 | 2,500 | 275,000 | | 275,000 |
| ថ្នាំការពារសត្វល្អិត និងជំងឺ | ដង | 6 | 33,000 | 198,000 | | 198,000 |
| ចំណាយបូមទឹកស្រោច(អគ្គិសនី) | ដង | 15 | 40,000 | 600,000 | | 600,000 |
| ចំណាយផ្សេងៗ | ឆ្នាំ | 1 | 100,000 | 100,000 | | 100,000 |
| ចំណាយលើការរំលស់ការរៀបចំប្រព័ន្ធទឹកស្រោចស្រព | ឈុត | 1 | 8,000,000 | 8,000,000* | 6 | 1,333,333 |

| | | | | | | |
|---|---|---|---|---|---|---|
| ចំណាយលើការរំលស់ប្រព័ន្ធលាយជីទឹកតាមទុយោដំណក់ | ឈុត | 1 | 800,000 | 800,000* | 6 | 133,333 |
| **II-ចំណាយថែទាំឆ្នាំទី ២** | | | | **10,876,250** | | **12,342,917** |
| កម្លាំងពលកម្ម | ឆ្នាំ | 1 | 1,000,000 | 1,000,000 | | 1,000,000 |
| ថ្នាំកម្ចាត់ស្មៅ | ដង | 3 | 80,000 | 240,000 | | 240,000 |
| ជីបំប៉នការលូតលាស់ (ជីសរីរាង្គ) | គ.ក្រ | 5,500 | 1,000 | 5,500,000 | | 5,500,000 |
| ជីបំប៉នការលូតលាស់ (ជី NPK) | គ.ក្រ | 302.5 | 2,500 | 756,250 | | 756,250 |
| ថ្នាំការពារសត្វល្អិត និងជំងឺ | ដង | 6 | 40,000 | 240,000 | | 240,000 |
| កម្មករកាត់ខ្មែងកាហ្វេ | ដង | 8 | 30,000 | 240,000 | | 240,000 |
| ឈ្នួលពង្រីករណ្ដៅតាមគល់នីមួយៗ | រណ្ដៅ | 1,100 | 2,000 | 2,200,000 | | 2,200,000 |
| ចំណាយបូមទឹកស្រោច(អគ្គិសនី) | ដង | 15 | 40,000 | 600,000 | | 600,000 |
| ចំណាយផ្សេងៗ | ឆ្នាំ | 1 | 100,000 | 100,000 | | 100,000 |
| ចំណាយលើការរំលស់ការរៀបចំប្រព័ន្ធទឹកស្រោចស្រព | ឈុត | 1 | 8,000,000 | 8,000,000 * | 6 | 1,333,333 |
| ចំណាយលើការរំលស់ប្រព័ន្ធលាយជីទឹកតាមទុយោដំណក់ | ឈុត | 1 | 800,000 | 800,000* | 6 | 133,333 |
| **ចំណាយបង្គរត្រឹមឆ្នាំទី២** -(I+II+III) | | | | **-33,019,875** | | **-27,153,208** |
| **IV-ចំណាយឆ្នាំទី ៣** | | | | **13,926,250** | | **14,912,917** |
| កម្លាំងពលកម្ម | ឆ្នាំ | 1 | 1,000,000 | 1,000,000 | | 1,000,000 |
| ថ្នាំកម្ចាត់ស្មៅ | ដង | 3 | 80,000 | 240,000 | | 240,000 |
| ជីបំប៉នការលូតលាស់ (ជីសរីរាង្គ) | គ.ក្រ | 5,500 | 1,000 | 5,500,000 | | 5,500,000 |
| ជីបំប៉នការលូតលាស់ (ជីNPK) | គ.ក្រ | 302.5 | 2,500 | 756,250 | | 756,250 |
| ថ្នាំការពារសត្វល្អិត និងជំងឺ | ដង | 8 | 40,000 | 320,000 | | 320,000 |
| កម្មករកាត់ខ្មែងកាហ្វេ | ដង | 6 | 30,000 | 180,000 | | 180,000 |
| ឈ្នួលពង្រីករណ្ដៅតាមគល់នីមួយៗ | រណ្ដៅ | 1,100 | 2,000 | 2,200,000 | | 2,200,000 |
| ចំណាយបូមទឹកស្រោច(អគ្គិសនី) | ដង | 15 | 60,000 | 900,000 | | 900,000 |
| ឈ្នួលពលកម្មបេះផ្លែកាហ្វេ ឆ្នាំទី៣ | គ.ក្រ | 5,500 | 300 | 1,650,000 | | 1,650,000 |
